ឯកឧត្តម ចម ប្រសិទ្ធ ជួបប្រតិភូសមាគមអាជីវកម្មទឹកស្អាតមកពីទីក្រុង **Kitakyushu** ប្រទេសជប៉ុន



នៅព្រឹកថ្ងៃទី០១ ខែ កញ្ញា ឆ្នាំ២០១៥ ឯកឧត្តម ចម ប្រសិទ្ធ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និង សិប្បកម្ម បានទទួលជួបប្រតិភូសមាគមអាជីវកម្មទឹកស្អាតមកពីទីក្រុង **Kitakyushu (KOWBA)** នៃប្រទេសជប៉ុន ដឹកនាំដោយលោក **Inoue Yasuto** ដើម្បីពិភាក្សាការងារ នៅទីស្តីការក្រសួង ។



ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានសម្តែងការស្វាគមន៍ និងវាយតម្លៃខ្ពស់ចំពោះ កិច្ចសហការដ៏ល្អ ព្រមទាំងថ្លែងអំណរគុណដល់សមាគមមកពីទីក្រុង Kitakyushu ដែលបានសហការជួយច្រើនលើវិស័យទឹកស្អាតនៅកម្ពុជា ជាពិសេសលើការបណ្តុះបណ្តាលធនធានមនុស្ស ទាំងក្នុងទីស្តីការក្រសួង និងរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ។



លោក **Inoue Yasuto** បានជម្រាបជូនពីគោលបំណងនៃជំនួបពិភាក្សា គឺសមាគមមានបេសកកម្មរយៈពេល១០ថ្ងៃ ដោយសហការជាមួយក្រុមហ៊ុនពីរទៀត គឺក្រុមហ៊ុន Yaskawa Electronic Corporation និង Uni-Elex ដើម្បីធ្វើការពិនិត្យវាយតម្លៃលើរបៀបសន្សំថាមពលអគ្គិសនី និងវិធានគ្រប់គ្រងភាពសមស្របនៃការចែកចាយទឹកជាដើម ។ ការចុះប្រតិបត្តិការនេះ ក្រុមការងារនឹងប្រើប្រាស់ស្ថានីយ៍ផលិតទឹកស្អាតឯកជនព្រៃគុប ជាស្ថានីយ៍គំរូ ។

លោក **Inoue Yasuto** បានជម្រាបជូនថាៈការអនុវត្តការងារនេះ គឺផ្អែកតាមលទ្ធផលនៃសិក្ខាសាលា កាលពីចុងឆ្នាំ ២០១៤ រៀបចំដោយសមាគម ឃើញថាវិស័យផ្គត់ផ្គង់ទឹកស្អាតរបស់ឯកជន នៅមានកង្វះខាតផ្នែកបច្ចេកទេស–ប្រព័ន្ធគ្រប់គ្រង និងកង្វះឥណទាន។ ល ។ ដូច្នេះ សមាគមសម្រេចអនុវត្តគម្រោង ចុះសិក្សាស្រាវជ្រាវ វាយតម្លៃ ដើម្បីបានជាលទ្ធផល សម្រាប់ជួយពង្រឹងវិស័យផ្គត់ផ្គង់ទឹកស្អាតឯកជននៅកម្ពុជា ។

ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានចាត់ទុកគម្រោងសិក្សាស្រាវជ្រាវនេះ មានផលប្រយោជន៍ណាស់ មិនត្រឹមសម្រាប់វិស័យ ឯកជនទេ តែសម្រាប់រដ្ឋផងដែរ ។ ដូច្នេះ ឯកឧត្តម បានស្នើឱ្យសមាគមទទួលយកមន្ត្រីជំនាញពីនាយកដ្ឋានទឹកស្អាតរបស់ក្រសួង និងពីសមាគមទឹកស្អាតកម្ពុជាមួយចំនួន ចូលក្នុងក្រុមការងារ ក្នុងន័យសម្រួលកិច្ចសហការ និងទទួលបានបទពិសោធន៍ពីការងារនេះ ។ ឯកឧត្តម បានធ្វើការបញ្ជាក់ថាៈការផ្គត់ផ្គង់វិស័យទឹកស្អាត ជាភារកិច្ចរបស់រដ្ឋ តែដោយលទ្ធភាពនៅមានកំរិត រដ្ឋបានផ្តល់សិទ្ធិវិនិយោគដល់វិស័យឯកជន នៅតំបន់ផ្សេងៗគ្នា ។ ប៉ុន្តែការវិនិយោគរបស់វិស័យឯកជន ធ្វើឱ្យតម្លៃទឹក មានភាពខុសគ្នាពីតំបន់មួយ ទៅតំបន់មួយ ដោយសារការចំណាយថ្លៃដើមខុសគ្នា ។ ហើយការចំណាយថ្លៃដើមខុសគ្នានេះ ក៏មានមូលហេតុជាច្រើនដែរ ដូចជាៈប្រភពទឹកខុសគ្នា–ការប្រើប្រាស់ឧបករណ៍មិនសមស្រប–ខ្វះការគ្រប់គ្រង ជាពិសេស គឺការប្រើប្រាស់បញ្ជីគណនេយ្យមិនត្រឹមត្រូវ ដែលបញ្ហានេះ ក្រសួងបានកំណត់ឱ្យវិស័យផ្គត់ផ្គង់ទឹកស្អាតទាំងរដ្ឋ និងឯកជន ចាប់អនុវត្តប្រើប្រាស់បញ្ជីគណនេយ្យតាមស្តង់ដារតែមួយ នៅដើមឆ្នាំ២០១៦ ខាងមុខនេះ ។

ឯកឧត្តមទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ សង្ឃឹមថាៈបេសកកម្មសិក្សាស្រាវជ្រាវរបស់សមាគមមកពីទីក្រុង Kitakyushu នឹងបង្ហាញលទ្ធផលវិជ្ជមាន សម្រាប់រកមូលហេតុជួយឱ្យវិស័យផលិតទឹកស្អាតឯកជននៅកម្ពុជា មានដំណើរទៅ

មុខប្រកបដោយជោគជ័យ និង មានការទទួលខុសត្រូវខ្ពស់លើអាជីវកម្មរបស់ខ្លួន ។ ឯកឧត្តម ក៏បានស្នើឱ្យតំណាងសមាគម យកលទ្ធផលស្រាវជ្រាវនេះ ធ្វើការផ្សព្វផ្សាយ ក្នុងសិក្ខាសាលានាពេលខាងមុខ ហើយក៏សូមឱ្យមានការរៀបចំកម្មវិធីផ្គូរផ្គង អាជីវកម្ម (Business Marching) និងការបង្ហាញផលិតផលគុណភាពខ្ពស់មកពីប្រទេសជប៉ុនផងដែរ ។

